# ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា

# Cambodia Public Debt Statistical Bulletin








ចេញផ្សាយលើកទី១ - ទិន្នន័យត្រឹមឆ្នាំ២០១៥

Volume 1 – Data as of 2015

រាជធានីភ្នំពេញ, ខែមិថុនា ឆ្នាំ២០១៦ / Phnom Penh, June 2016

# អារម្ភកថា

រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨ នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ និងបានធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ដែលបានដាក់ចេញនូវគោលការណ៍គន្លឹះចំនួន ០៤ គឺ៖ ១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន; ២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់; ៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច; និង ៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

ទន្ទឹមនេះ ដើម្បីបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប សំដៅរួមចំណែកជំរុញចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងលើកស្ទួយកម្រិតជីវភាពប្រជាជន រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយលម្អិតចំនួន ០៩ ចំណុច សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៥-២០១៨ ដូចខាងក្រោម៖

១- កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។ សម្រាប់ឆ្នាំ២០១៥-២០១៨ ជារួម រាជរដ្ឋាភិបាលនឹងមិនបោះផ្សាយមូលបត្ររដ្ឋ ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យដែលជាឧបករណ៍បំណុលថ្មីទេ តែក៏អាចធ្វើការសាកល្បងប្រើប្រាស់ឧបករណ៍ថ្មីនេះនៅពេលណាមួយ សម្រាប់ជាការចាប់ផ្តើមនៃទីផ្សារបំណុល (មូលបត្ររដ្ឋ) និងអាចជាមូលដ្ឋានសម្រាប់ឱ្យមានការបោះផ្សាយមូលបត្រឯកជន។

២- បន្តប្រើប្រាស់ឥណទានសម្បទានសម្រាប់ហិរញ្ញប្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង។

៣- បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។

៤- បន្តទទួលយកតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

៥- បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ សំដៅសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ ៧ ភាគរយ និងកំណើនចំណូលថវិកាជាតិក្នុងរង្វង់ជាមធ្យម ០,៥ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ។

៦- បន្តអនុវត្តគោលការណ៍មជ្ឈការក្នុងការគ្រប់គ្រងបំណុលសាធារណៈ។

៧- បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀត សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។

៨- បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃកាតព្វកិច្ចបំណុលដោយថាហេតុដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោង PPP និង ពីវិស័យធនាគារ និងហិរញ្ញវត្ថុ។

៩- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងគោលបំណងបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដូចមានចែងក្នុងមាត្រា ៣៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី៣ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈលើកទី១ នេះ ឱ្យលេចចេញជារូបរាង ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដើម្បីបោះផ្សាយ និងផ្សព្វផ្សាយជាសាធារណៈ។ ការសម្រេចបាននូវព្រឹត្តិបត្រនេះ គឺជាសមិទ្ធផលថ្មីមួយបន្ថែមទៀត ក្នុងចំណោមសមិទ្ធផលធំៗ ដែលសម្រេចបានកន្លងមក ក្នុងកិច្ចការពង្រឹងការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល។

ព្រឹត្តិបត្រនេះ ត្រូវបានរៀបចំដោយអនុលោមតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ដោយមានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី៖ ១) បំណុលសាធារណៈក្នុងប្រទេស; ២) បំណុលសាធារណៈក្រៅប្រទេស; និង ៣) ការផ្តល់ឥណទានរបស់រដ្ឋដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកអានទិន្នន័យទាំងអស់ត្រូវបានបែងចែកជា ០៤ ក្រុម គឺ៖ ១) ការខ្ចី, ២) ការដកសាច់ប្រាក់, ៣) សេវាបំណុល (ការទូទាត់ជូនឥណទាយក និងការប្រមូលពីឥណទានយិកក្រោមក្របខ័ណ្ឌនៃការផ្តល់ឥណទានរបស់រដ្ឋ), និង ៤) សន្និធិបំណុល ហើយដែលត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ វិស័យ, ឥណទាយក/ឥណទាយិក, និងរូបិយប័ណ្ណ។

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ត្រូវបានរៀបរៀង និងបោះផ្សាយជាទៀងទាត់ រៀងរាល់មួយឆមាសម្តង ជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស។ បើទោះបីជាយ៉ាងដូចនេះក្តី ចំពោះព្រឹត្តិបត្រលេខដំបូងនេះ ទិន្នន័យត្រូវបានរៀបចំ និងបោះផ្សាយសម្រាប់ប្រចាំឆ្នាំតែម្តង (គឺឆ្នាំ២០១៥) ហើយនៅលេខបន្ទាប់ នឹងត្រូវរៀបចំ និងបោះផ្សាយតាមឆមាស។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ខ្ញុំជឿជាក់ថា ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ ពិតជាអាចបង្កើនការយល់ដឹងបន្ថែមជូនសាធារណជន ក៏ដូចជាតួអង្គពាក់ព័ន្ធទាំងឡាយ ជ្រួតជ្រាបកាន់តែច្បាស់អំពីស្ថានភាពបំណុលសាធារណៈជាក់ស្តែងរបស់កម្ពុជា។ ទន្ទឹមនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ព្រឹត្តិបត្រនេះ នឹងទទួលបាននូវការគាំទ្រ និងលើកទឹកចិត្ត ពីអ្នកអានទាំងអស់ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមស្វាគមន៍នូវរាល់មតិយោបល់ក្នុងន័យស្ថាបនា ដើម្បីកែលម្អព្រឹត្តិបត្រលេខក្រោយៗ ឱ្យកាន់តែប្រសើរថែមទៀត។

*រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦*

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

## Table of Contents


ទំព័រ / Page

**ជំពូក ១៖ ព័ត៌មានទូទៅ / Chapter I: General Information**

ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations ........ ១ / 1

ខ- វិសាលភាព / B- Coverage ........ ១ / 1

គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ / C- Grouping and Classification ........ ១ / 1

ឃ- ប្រភពទិន្នន័យ / D- Sources ........ ១ / 1

ង- ការបំប្លែងរូបិយប័ណ្ណ / E- Currency Conversion ........ ២ / 2

ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ / F- Revision Policy ........ ២ / 2

ឆ- ការបោះផ្សាយ / G- Frequency and Time Lag ........ ២ / 2

ជ- និយមន័យ / H- Definitions ........ ៣ / 3

**ជំពូក ២៖ តារាងស្ថិតិ / Chapter II: Statistical Tables**

តារាងទី១៖ អត្រាប្តូរប្រាក់ / Table 1: Exchange Rates ........ ៧ / 7

តារាងទី២៖ សូចនាករបំណុល / Table 2: Debt Indicators ........ ៨ / 8

តារាងទី៣៖ សូចនាករថ្លៃ និងហានិភ័យ / Table 3: Cost - Risk Indicators ........ ៩ / 9

តារាងទី៤៖ ការខ្ចី, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល / ........ ១០

Table 4: Borrowing, Disbursement, Debt Service Payment, and Outstanding ........ 10

**ផ្នែកទី ១៖ បំណុលសាធារណៈក្រៅប្រទេស / Part 1: Public External Debt**

**១.១. ការខ្ចី / 1.1. Borrowing**

តារាងទី៥៖ ការខ្ចីតាមវិស័យ / Table 5: Borrowing by Sector ........ ១១ / 11

តារាងទី៦៖ ការខ្ចីតាមឥណទាយក / Table 6: Borrowing by Creditor ........ ១២ / 12

តារាងទី៧៖ ការខ្ចីតាមរូបិយប័ណ្ណ / Table 7: Borrowing by Currency ........ ១៣ / 13

**១.២. ការដកសាច់ប្រាក់ / 1.2. Disbursement**

តារាងទី៨៖ ការដកសាច់ប្រាក់តាមវិស័យ / Table 8: Disbursement by Sector ........ ១៤ / 14

តារាងទី៩៖ ការដកសាច់ប្រាក់តាមឥណទាយក / Table 9: Disbursement by Creditor ........ ១៥ / 15

តារាងទី១០៖ ការដកសាច់ប្រាក់តាមរូបិយប័ណ្ណ / Table 10: Disbursement by Currency ........ ១៦ / 16

**១.៣. ការទូទាត់សេវាបំណុល / 1.3. Debt Service Payment**

តារាងទី១១៖ ការទូទាត់សេវាបំណុលតាមឥណទាយក / ........ ១៧

Table 11: Debt Service Payment by Creditor ........ 17

តារាងទី១២៖ ការទូទាត់សេវាបំណុលតាមរូបិយប័ណ្ណ / ........ ១៨

Table 12: Debt Service Payment by Currency ........ 18

**១.៤. សន្និធិបំណុល / 1.4. Outstanding**

តារាងទី១៣៖ សន្និធិបំណុលតាមឥណទាយក / Table 13: Outstanding by Creditor ........ ១៩ / 19

តារាងទី១៤៖ សន្និធិបំណុលតាមរូបិយប័ណ្ណ / Table 14: Outstanding by Currency ........ ២០ / 20

ផ្នែកទី ២៖ បំណុលសាធារណៈក្នុងប្រទេស / Part 2: Public Domestic Debt
តារាងទី១៥៖ ការទូទាត់សេវាបំណុល និងសន្និធិបំណុលសាធារណៈក្នុងប្រទេស / ........................................ ២១
Table 15: Public Domestic Debt Service Payment and Outstanding ............................................ 21

ផ្នែកទី ៣៖ ការផ្តល់ឥណទានរបស់រដ្ឋ / Part 3: Government Lending and On-lending
តារាងទី១៦៖ ការផ្តល់ឥណទាន, ការដកសាច់ប្រាក់, ការប្រមូលសេវាបំណុល, និងសន្និធិបំណុល /.................. ២២
Table 16: Lending and On-lending, Disbursement, Debt Service Collection, and Outstanding ..... 22

៣.១. ការផ្តល់ឥណទាន / 3.1. Lending and On-lending
តារាងទី១៧៖ ការផ្តល់ឥណទានតាមវិស័យ / Table 17: Lending and On-lending by Sector ............ ២៣ / 23
តារាងទី១៨៖ ការផ្តល់ឥណទានតាមឥណទាយិក / Table 18: Lending and On-lending by Debtor ......... ២៤ / 24
តារាងទី១៩៖ ការផ្តល់ឥណទានតាមរូបិយប័ណ្ណ / Table 19: Lending and On-lending by Currency ....... ២៥ / 25

៣.២. ការដកសាច់ប្រាក់ / 3.2. Disbursement
តារាងទី២០៖ ការដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមវិស័យ / .................................... ២៦
Table 20: Lending and On-lending Disbursement by Sector ........................................................ 26
តារាងទី២១៖ ការដកសាច់ប្រាក់តាមឥណទាយិក / .................................................................................... ២៧
Table 21: Disbursement by Debtor ............................................................................................ 27
តារាងទី២២៖ ការដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមរូបិយប័ណ្ណ / .............................. ២៨
Table 22: Lending and On-lending Disbursement by Currency ................................................... 28

៣.៣. ការប្រមូលសេវាបំណុល / 3.3. Debt Service Collection
តារាងទី២៣៖ ការប្រមូលសេវាបំណុលតាមឥណទាយិក / ........................................................................ ២៩
Table 23: Debt Service Collection by Debtor ................................................................................ 29

៣.៤. សន្និធិបំណុល / 3.4. Outstanding
តារាងទី២៤៖ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមឥណទាយិក / ................................ ៣០
Table 24: Lending and On-lending Outstanding by Debtor ............................................................ 30
តារាងទី២៥៖ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមរូបិយប័ណ្ណ /.................................... ៣១
Table 25: Lending and On-lending Outstanding by Currency ...................................................... 31

ផ្នែកទី ៤៖ ការព្យាករណ៍ / Part 4: Projections
តារាងទី២៦៖ ព្យាករណ៍ការខ្ចីក្រៅប្រទេស, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល /....... ៣២
Table 26: Projections of External Borrowing, Disbursement, Debt Service Payment, and Outstanding ...... 32
តារាងទី២៧៖ ព្យាករណ៍ការដកសាច់ប្រាក់ និងការប្រមូលសេវាបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋ /.... ៣៣
Table 27: Projections of Lending and On-lending Disbursement and Debt Service Collection ...... 33
តារាងទី២៨៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ តាមរូបិយប័ណ្ណ ក្នុងឆ្នាំ២០១៦ /................................ ៣៤
Table 28: Projections of Monthly Debt Service Payment by Currency in 2016 ............................... 34
តារាងទី២៩៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៦-២០២០ /.................................. ៣៥
Table 29: Projections of Monthly Debt Service Payment for 2016-2020 ........................................ 35

ជំពូក ៣៖ ក្រាហ្វ / Chapter 3: Graphs


ក្រាហ្វទី១៖ ការខ្ចីក្រៅប្រទេស (ប្រចាំឆ្នាំ និងសរុបត្រឹមឆ្នាំ២០១៥) /....................៣៦

Graph 1: External Borrowing (Annual and Accumulated as of 2015) ....................36

ក្រាហ្វទី២៖ ការដកសាច់ប្រាក់ (ប្រចាំឆ្នាំ និងសរុបត្រឹមឆ្នាំ២០១៥) / ....................៣៧

Graph 2: Disbursement (Annual and Accumulated as of 2015) ....................37

ក្រាហ្វទី៣៖ ការទូទាត់សេវាបំណុលក្រៅប្រទេស (ប្រចាំឆ្នាំ និងសរុបត្រឹមឆ្នាំ២០១៥) /....................៣៨

Graph 3: External Debt Service Payment (Annual and Accumulated as of 2015) ....................38

ក្រាហ្វទី៤៖ សន្និធិបំណុលសាធារណៈ / ....................៣៩

Graph 4: Public Debt Outstanding.................... 39

ក្រាហ្វទី៥៖ ការផ្តល់ឥណទានរបស់រដ្ឋ (ប្រចាំឆ្នាំ និងសរុបត្រឹមឆ្នាំ២០១៥) /.................... ៤០

Graph 5: Government Lending and On-lending (Annual and Accumulated as of 2015) ....................40

ក្រាហ្វទី៦៖ ការដកសាច់ប្រាក់ពីរដ្ឋ (ប្រចាំឆ្នាំ និងសរុបត្រឹមឆ្នាំ២០១៥) / .................... ៤១

Graph 6: Lending and On-lending Disbursement (Annual and Accumulated as of 2015) .................... 41

ក្រាហ្វទី៧៖ ការប្រមូលសេវាបំណុល និងសន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋ /....................៤២

Graph 7: Lending and On-lending Debt Service Collection and Outstanding....................42

ក្រាហ្វទី៨៖ ព្យាករណ៍ការទូទាត់សេវាបំណុលប្រចាំខែ សម្រាប់ឆ្នាំ២០១៦-២០២០ /....................៤៣

Graph 8: Projections of Monthly Debt Service Payment for 2016-2020....................43

# ជំពូក ១

# ព័ត៌មានទូទៅ

# Chapter I

# General Information

## ក- ពាក្យបំព្រួញ / A- Acronyms and Abbreviations

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CNY | Chinese Yuan Renminbi | យ័នចិន |
| EUR | Euro | អឺរ៉ូ |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| JPY | Japanese Yen | យ៉េនជប៉ុន |
| KHR | Khmer Riel | រៀលខ្មែរ |
| KRW | Korean Won | វ៉ុនកូរ៉េ |
| MYR | Malaysian Ringgit | រីងហ្គីតម៉ាឡេស៊ី |
| NDF | Nordic Development Fund | មូលនិធិអភិវឌ្ឍន៍ណ័រឌីក |
| OFID | OPEC Fund for International Development | មូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| SDR | Special Drawing Rights | អេសដេអ៊ែរ |
| THB | Thai Baht | បាតថៃ |
| USD | United States Dollar | ដុល្លារអាមេរិក |
| WB | World Bank | ធនាគារពិភពលោក |

## ខ- វិសាលភាព

ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈនេះ មានវិសាលភាពគ្របដណ្តប់លើទិន្នន័យស្តីពី៖ ១) បំណុលសាធារណៈក្រៅប្រទេស, ២) បំណុលសាធារណៈក្នុងប្រទេស, និង ៣) ការផ្តល់ឥណទានរបស់រដ្ឋ។

## B. Coverage

This public debt statistical bulletin covers data on: 1) Public Domestic Debt, 2) Public External Debt, and 3) Government Lending and On-lending.

## គ- ក្រុម និងចំណាត់ប្រភេទទិន្នន័យ

ទិន្នន័យក្នុងព្រឹត្តិបត្រនេះ ត្រូវបានបែងចែកជា ០៤ ក្រុម គឺ៖ ១) ការខ្ចី, ២) ការដកសាច់ប្រាក់, ៣) សេវាបំណុល (ការទូទាត់ និងការប្រមូល), និង ៤) សន្និធិបំណុល។

បន្ថែមលើនេះ ទិន្នន័យត្រូវបានចាត់ចំណាត់ប្រភេទទៅតាម៖ ១) វិស័យ, ២) ឥណទាយក/ឥណទាយិក, និង ៣) រូបិយប័ណ្ណ។

## C. Grouping and Classification

Data in this bulletin are grouped in 04 categories: 1) Borrowing, 2) Disbursement, 3) Debt Service (Payment and Collection), and 4) Outstanding.

Furthermore, the data are classified by: 1) Sector, 2) Creditor/Debtor, and 3) Currency.

## ឃ- ប្រភពទិន្នន័យ

ទិន្នន័យ សម្រាប់ប្រើជាមូលដ្ឋានក្នុងការរៀបចំព្រឹត្តិបត្រនេះ មានប្រភព ដូចខាងក្រោម៖

– ទិន្នន័យបំណុល៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច

## D. Sources

The sources of data used for preparing this bulletin are as below:

- Debt data: General Department of International Cooperation and Debt

និងហិរញ្ញវត្ថុ។
- ទិន្នន័យម៉ាក្រូសេដ្ឋកិច្ច៖ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ទិន្នន័យអត្រាប្តូរប្រាក់៖ ធនាគារជាតិនៃកម្ពុជា។

Management, Ministry of Economy and Finance.
- Macro-economic data: General Department of Economic and Public Finance Policy, Ministry of Economy and Finance.
- Exchange rates data: National Bank of Cambodia.

## ង- ការបំប្លែងរូបិយប័ណ្ណ

ការបំប្លែងរូបិយប័ណ្ណ ត្រូវបានអនុវត្តតាមវិធីសាស្ត្រជាបទដ្ឋានបច្ចេកទេសអន្តរជាតិ ដូចខាងក្រោម៖
- ការខ្ចី៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា (ថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូ)។
- ការដកសាច់ប្រាក់៖
  - ប្រចាំឆមាស/ឆ្នាំ៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃដកសាច់ប្រាក់ជាក់ស្តែង។
  - សរុប៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
- សេវាបំណុល៖
  - ប្រចាំឆមាស/ឆ្នាំ៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃទូទាត់/ប្រមូល សេវាបំណុលជាក់ស្តែង។
  - សរុប៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
- សន្និធិបំណុល៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។
- ការព្យាករណ៍៖ គិតតាមអត្រាប្តូរប្រាក់នៅថ្ងៃចុងគ្រា។

## E. Currency Conversion

The international best practice approach has been applied for the currency conversion as follows:
- Borrowing: converted by the exchange rates at end-period (on 30 June or 31 December).
- Disbursement:
  - Semi-annual/Annual: converted by exchange rates on actual disbursement date.
  - Accumulated: converted by the exchange rates at end-period.
- Debt Service:
  - Semi-annual/Annual: converted by exchange rates on actual debt service payment/collection date.
  - Accumulated: converted by the exchange rates at end-period.
- Outstanding: converted by the exchange rates at end-period.
- Projections: converted by the exchange rates at end-period.

## ច- គោលនយោបាយក្នុងការកែតម្រូវទិន្នន័យ

តួលេខមួយចំនួននៅក្នុងព្រឹត្តិបត្រនេះ ត្រូវបានកែតម្រូវពីតួលេខដែលបានរាយការណ៍កន្លងមក ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក៏អាចនឹងត្រូវបានកែតម្រូវនៅក្នុងការបោះផ្សាយលើកក្រោយផងដែរ។ តួលេខទាំងឡាយណាដែលមានគូសបន្ទាត់ពីក្រោម បញ្ជាក់ថាជាតួលេខដែលបានកែតម្រូវ។

## F. Revision Policy

Some figures in this bulletin have been revised from the figures previously reported by the Ministry of Economy and Finance and might also be revised in the next edition. The figures with underline are the revised figures.

## ឆ- ការបោះផ្សាយ

ក្នុងដំណាក់កាលបឋម ព្រឹត្តិបត្រនេះ នឹងត្រូវបានបោះផ្សាយមួយឆមាសម្តង ក្នុងរយៈពេលមិនលើសពី ០៦ ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ ហើយនៅដំណាក់កាលបន្ទាប់ ក្នុងរយៈពេលមិនលើសពី ០៣ ខែ បន្ទាប់ពីដំណាច់ឆមាសនីមួយៗ។

## G. Frequency and Time Lag

The bulletin will be published on a semi-annual basis within time lag of 06 months at the preliminary stage and 03 months at the later stage.

## ជ- និយមន័យ

និយមន័យនៃវាក្យស័ព្ទគន្លឹះៗ ដែលប្រើប្រាស់ក្នុងព្រឹត្តិបត្រនេះ មានដូចខាងក្រោម៖

- **បំណុលសាធារណៈក្រៅប្រទេស៖** សំដៅដល់បំណុលក្រៅប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយមិនគិតបញ្ចូលបំណុលដែលពុំមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះមានតែ ការខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍ ទ្វេភាគី និងពហុភាគីក្រៅប្រទេស ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលនូវ សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យផងដែរ ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

- **បំណុលសាធារណៈក្នុងប្រទេស៖** សំដៅដល់បំណុលក្នុងប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយមិនគិតបញ្ចូលនូវបំណុលដែលពុំមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បំណុលនេះ មានតែសញ្ញាប័ណ្ណរដ្ឋមិនអាចជួញដូរបាន ដែលរាជរដ្ឋាភិបាលបានបោះផ្សាយ ដើម្បីបំពេញទុនឱ្យក្រុមហ៊ុនធានារ៉ាប់រងរបស់រដ្ឋប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលនូវសញ្ញាប័ណ្ណរដ្ឋដែលអាចជួញដូរបានផងដែរ ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។

- **ការផ្តល់ឥណទានរបស់រដ្ឋ៖** សំដៅដល់ការឱ្យប្រាក់ដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ខ្ចី ដោយប្រើប្រាស់ថវិការដ្ឋ ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។

## H. Definitions

Terminologies used in this bulletin are defined as follows:

- **Public External Debt:** refers to the external debts of the government incurred under the applicable laws and excluding non-guaranteed debts. In Cambodia's current context, the public external debt comprises only concessional loans from bilateral and multilateral external development partners. However, this debt, in the future, would also include sovereign bonds in case of issuance decided by the RGC.

- **Public Domestic Debt:** refers to the internal debts of the government incurred under the applicable laws and excluding non-guaranteed debts. In Cambodia's current context, the public domestic debt comprises only non-marketable government bonds issued by the Royal Government of Cambodia (RGC) to recapitalize its state-owned insurance companies. However, this debt, in the future, would also include marketable government bonds in case of issuance decided by the RGC.

- **Government Lending and On-lending:** refers to the credits provided by the government under government budget or development partners' financing to state-owned enterprises, public institutions, legal entities, and banking and financial institutions for the purpose of supporting socio-economic development.

- **ការខ្ចី៖** សំដៅដល់ទំហំឥណទានដែលរដ្ឋចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍។

- **Borrowing:** refers to the amount of loans that the government signed in the agreement with development partners.

- **ការដកសាច់ប្រាក់៖** សំដៅដល់សាច់ប្រាក់ដែលឥណទាយកបានអនុញ្ញាតឱ្យឥណទាយិក ដកយកមកប្រើប្រាស់ជាក់ស្តែង ក្នុងការអនុវត្តគម្រោង/កម្មវិធី។

- **Disbursement:** refers to proceeds or cash a creditor agreed with a debtor on the withdrawal for actual expenses in implementing a project / program.

- **សេវាបំណុល៖** សំដៅដល់ប្រាក់ដើម, ការប្រាក់, និងកម្រៃពាក់ព័ន្ធផ្សេងទៀត។

- **Debt Service:** refers to principal, interest, and other fees.

- **សន្និធិបំណុល៖** សំដៅដល់ទំហំបំណុលជាក់ស្តែងដែលឥណទាយិកមិនទាន់ទូទាត់ជូនឥណទាយក។ ជាទូទៅ សន្និធិបំណុល ស្មើនឹងការដកសាច់ប្រាក់សរុបដកឱ្យការទូទាត់ប្រាក់ដើមសរុប។

- **Outstanding:** refers to actual amount of unpaid debts that the debtor has to pay to the creditor. Commonly, outstanding equals to the total disbursements minus the total repaid principal.

- **បំណុលចាស់៖** សំដៅដល់បំណុលដែលបន្សល់ទុកដោយរដ្ឋាភិបាលជំនាន់មុន។ ក្នុងបរិការណ៍កម្ពុជា បំណុលចាស់ គឺជាបំណុលដែលបានកើតឡើងមុនឆ្នាំ ១៩៩៣។ ភាគច្រើននៃបំណុលទាំងនេះ ត្រូវបានចរចាដោះស្រាយជាមួយដៃគូរួចរាល់ហើយ ក្នុងនោះ មួយចំនួនត្រូវបានទូទាត់សងរួចរាល់ជាស្ថាពរ និងមួយចំនួនកំពុងត្រូវបានទូទាត់តាមកម្មវិធីសងក្នុងកិច្ចព្រមព្រៀង។ ដោយឡែក ចំពោះបំណុលចាស់ដែលនៅសេសសល់ បច្ចុប្បន្ន រាជរដ្ឋាភិបាល បាននិងកំពុងខិតខំបន្តដោះស្រាយជាមួយដៃគូ ឱ្យបានជ្រះស្រឡះ។

- **Old Debts:** refers to legacy debts inherited from the previous governments. In Cambodia's context, old debts refer to ones incurred before 1993. Most old debts have been already resolved with partners; some of them were fully paid back while some others have been being repaid based on the rescheduling agreements. Concerning the remaining old debts, the RGC has been making the effort to find clear-cut resolutions with partners.

- **ឥណទាយក៖** សំដៅដល់ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី ដែលផ្តល់ឥណទានឱ្យរដ្ឋខ្ចី ដូចជា៖ ចិន, ជប៉ុន, សាធារណរដ្ឋកូរ៉េ, បារាំង, ធនាគារអភិវឌ្ឍន៍អាស៊ី, និងធនាគារពិភពលោក ជាដើម។

- **Creditor:** refers to both bilateral and multilateral development partners who provided loans to the RGC such as: China, Japan, Republic of Korea, France, ADB, and WB, etc.

- **ឥណទាយិក៖** សំដៅដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានឥណទានពីរដ្ឋ។

- **Debtor:** refers to state-owned enterprises, public institutions, legal entities, and banking and financial institutions, which receive loan/sub-loan from the government.

- **តម្លៃបច្ចុប្បន្ននៃបំណុល៖** សំដៅដល់ទំហំសន្និធិបំណុលក្រោយដកធាតុអំណោយ។ តាមបទដ្ឋានបច្ចេក-ទេសអន្តរជាតិ ក្នុងការគណនាអនុបាតបំណុល គេមិនប្រើតម្លៃចារឹកនៃបំណុលទេ គឺគេប្រើតម្លៃបច្ចុប្បន្ននៃបំណុល។ ចំពោះកម្ពុជាក៏ដូចគ្នាដែរ គឺត្រូវប្រើតម្លៃបច្ចុប្បន្ននៃបំណុល ព្រោះថា ឥណទានដែលរដ្ឋខ្ចីពីក្រៅប្រទេសទាំងអស់សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

- **Present Value (PV) of Debts:** refers to the outstanding amount of debts after the deduction of grant element. According to international best practices, debt ratios are calculated by using the PV of debts instead of the Face Value. Similarly, this approach is also applied in Cambodia since all external loans are highly concessional.

- **ធាតុអំណោយ៖** សំដៅដល់ផលធៀបរវាង ១) ផលដកនៃតម្លៃចារឹករបស់ឥណទាន និងតម្លៃបច្ចុប្បន្ននៃការទូទាត់សេវាបំណុល និង ២) តម្លៃចារឹករបស់ឥណទាន។ ធាតុអំណោយ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវាស់ស្ទង់កម្រិតសម្បទាននៃឥណទាន។

- **Grant Element:** refers to the proportion between 1) the difference between the Face Value of the loan and the PV of future debt service payments, and 2) the Face Value of the loan. Grant Element is used to measure the concessionality of a loan.

- **តម្លៃចារឹកនៃបំណុល៖** សំដៅដល់ទំហំសន្និធិបំណុលដែលពុំទាន់ដកធាតុអំណោយ។

- **Face Value of Debts:** refers to the outstanding amount of debts before the deduction of grant element.

- **ក្លឹបប៉ារីស៖** សំដៅដល់ក្រុមឥណទាយក ដែលបង្កើតឡើងក្នុងគោលបំណងផ្តល់ការអនុគ្រោះបំណុលដល់ឥណទាយិកដែលពុំមានលទ្ធភាពក្នុងការទូទាត់សងបំណុល។ បច្ចុប្បន្ន ក្លឹបប៉ារីស មានសមាជិកអចិន្ត្រៃយ៍ចំនួន ២០ ប្រទេស រួមមាន៖ អូស្ត្រាលី, អូទ្រីស, បែលហ្ស៊ិក, កាណាដា, ដាណឺម៉ាក, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, អៀរឡង់, អ៊ីស្រាអែល, អ៊ីតាលី, ជប៉ុន, ហូឡង់, ន័រវែស, រុស្ស៊ី, អេស្ប៉ាញ, ស៊ុយអែត, ស្វ៊ីស, ចក្រភពអង់គ្លេស, និងសហរដ្ឋអាមេរិក។

- **Paris Club**: is a group of creditor countries aiming at addressing old debts issues for debtor countries experiencing debt repayment difficulties. At present, the Paris Club is comprised of 20 permanent country members including: Australia, Austria, Belgium, Canada, Denmark, Finland, France, Germany, Ireland, Israel, Italy, Japan, Netherlands, Norway, Russian Federation, Spain, Sweden, Switzerland, UK, and USA.

- **ឥណប្រតិទាន៖** សំដៅដល់រយៈពេលត្រូវសងបំណុលសរុប ដោយគិតចាប់ពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទាន ចូលជាធរមាន រហូតដល់បំណុលត្រូវបានសងអស់។ ឥណ-ប្រតិទាន ស្មើនឹងរយៈពេលអនុគ្រោះ បូកនឹងរយៈពេលសងដើម។

- **Maturity:** refers to the period from the date of signature of the loan to the last payment of the principal. Maturity is the sum of grace period and repayment period.

- **រយៈពេលអនុគ្រោះ៖** សំដៅដល់រយៈពេលចន្លោះពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬកិច្ចព្រមព្រៀងស្តីពីការផ្តល់ឥណទានចូលជាធរមាន រហូតដល់ពេលត្រូវសងប្រាក់ដើមដំបូង ដោយក្នុងរយៈពេលនោះ មានតែការប្រាក់ប៉ុណ្ណោះ ដែលត្រូវទូទាត់។

- **Grace Period:** refers to the period from the loan effective date to the first repayment of principal and only interest is charged during this period.

- **រយៈពេលមធ្យមដល់ឥណប្រតិទាន៖** សំដៅដល់រយៈពេលមធ្យមនៃការទូទាត់ប្រាក់ដើម គិតពីរយៈពេលជាក់លាក់ណាមួយ រហូតដល់ឥណប្រតិទាន។

- **Average Time to Maturity (ATM):** refers to the weighted average time of principal repayments int the portfolio, starting from a specific period to the maturity.

- **វិស័យហេដ្ឋារចនាសម្ព័ន្ធ** រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី, ការផ្គត់ផ្គង់ទឹកស្អាត, និងស្ថានីយ៍សម្អាតទឹកកខ្វក់។

- **Infrastructure** includes: roads, bridges, railways, ports, airports, irrigation systems, electricity, water supply, and waste water treatment.

- **វិស័យអាទិភាពផ្សេងទៀត** រួមមាន៖ សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, និងដីធ្លី។

- **Other priority sectors** include: economy, finance, tourism, education, public services, health, and land management.

# ជំពូក ២

# តារាងស្ថិតិ

# Chapter II

# Statistical Tables

តារាងទី១ / Table 1:

**អត្រាប្តូរប្រាក់ / Exchange Rates**

ធៀបនឹងដុល្លារអាមេរិក / Other Currencies vs. USD

| រូបិយប័ណ្ណ / Currency | 31-12-2013 | 31-12-2014 | 31-12-2015 |
|---|---|---|---|
| KHR | 3,995 | 4,075 | 4,050 |
| CNY | 6.030189 | 6.169569 | 6.459330 |
| EUR | 0.720794 | 0.818273 | 0.909908 |
| JPY | 104.417146 | 118.856643 | 119.875684 |
| KRW | 1,048.556430 | 1,089.572193 | 1,170.520231 |
| MYR | 3.271908 | 3.476962 | 4.269900 |
| SDR | 0.646126 | 0.687010 | 0.717449 |
| THB | 32.612245 | 32.730924 | 36.000000 |

តារាងទី២ / Table 2:

**សូចនាករបំណុល** / Debt Indicators

ជាភាគរយ / Percentage

| អនុបាត / Ratio | អនុបាតគោល / Threshold | 2013 | 2014 | 2015 |
|---|---|---|---|---|
| I. តម្លៃបច្ចុប្បន្ននៃបំណុលក្រៅប្រទេស / PV of External Debt | | | | |
| - ធៀបនឹង ផសស / to GDP | 40 | 23.1 | 23.1 | 23.2 |
| - ធៀបនឹង ការនាំចេញ / to Exports | 150 | 35.7 | 34.5 | 33.5 |
| - ធៀបនឹង ចំណូលថវិកាជាតិ / to Revenue | 250 | 155.3 | 151.7 | 147.6 |
| II. សេវាបំណុល / Debt Service | | | | |
| - ធៀបនឹង ការនាំចេញ / to Exports | 20 | 1.1 | 1.0 | 1.3 |
| - ធៀបនឹង ចំណូលថវិកាជាតិ / to Revenue | 20 | 5.1 | 4.6 | 5.7 |

កំណត់សម្គាល់ / Technical Notes:

*1- អនុបាតគោលទាំងនេះ គឺកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក /*

*The thresholds are defined by the IMF and World Bank for the medium policy countries*

*2- ទិន្នន័យទាំងអស់ផ្អែកលើការវិភាគចីរភាពបំណុលតាមបទដ្ឋានបច្ចេកទេសអន្តរជាតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /*

*All the figures here are based on DSA exercise which is done by MEF.*

តារាងទី៣ / Table 3:

**សូចនាករថ្លៃ និងហានិភ័យ** / Cost - Risk Indicators

| សូចនាករ / Indicator | 2013 | 2014 | 2015 |
|---|---|---|---|
| សមាសភាគបំណុលសាធារណៈជារូបិយប័ណ្ណបរទេស / Share of Foreign Currency in Total Public Debt | 99.87% | 99.89% | 99.94% |
| រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ) / Average Time to Maturity - "ATM" (Year) | 11.68 | 11.18 | 10.75 |
| អត្រាការប្រាក់មធ្យម / Weighted Average Interest Rate | 0.95% | 1.27% | 1.03% |
| ឥណប្រតិទានមធ្យម (ឆ្នាំ) / Weighted Average Maturity (Year) | 27.63 | 28.23 | 29.31 |
| រយៈពេលអនុគ្រោះមធ្យម (ឆ្នាំ) / Weighted Average Grace Period (Year) | 8.65 | 8.52 | 8.62 |
| ធាតុអំណោយមធ្យម / Weighted Average Grant Element | 46.18% | 44.77% | 48.32% |

តារាងទី៤ / Table 4:

**ការខ្ចី, ការដកសាច់ប្រាក់, ការទូទាត់សេវាបំណុល, និងសន្និធិបំណុល / Borrowing, Disbursement, Debt Service Payment, and Outstanding**

ឯកតា÷ ប៊ីលានរៀល, លានដុល្លារអាមេរិក / Unit: KHR Billion, USD Million

| បរិយាយ / Description | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | KHR | USD | KHR | USD | KHR | USD | KHR | USD | % |
| **I. ការខ្ចី / Borrowing** | **3,211.14** | **803.79** | **3,032.29** | **744.12** | **3,152.54** | **778.40** | **31,079.83** | **7,674.03** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | 2.40 | 0.60 | - | - | - | - | 79.49 | 19.63 | *0.26%* |
| - ក្រៅប្រទេស / External | 3,208.74 | 803.19 | 3,032.29 | 744.12 | 3,152.54 | 778.40 | 31,000.34 | 7,654.40 | *99.74%* |
| **II. ការដកសាច់ប្រាក់ / Disbursement** | **2,459.94** | 610.67 | **2,620.90** | 648.42 | **2,416.67** | **595.28** | **21,871.93** | **5,400.48** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | 2.40 | 0.60 | - | - | - | - | 79.49 | 19.63 | *0.36%* |
| - ក្រៅប្រទេស / External | 2,457.54 | 610.07 | 2,620.90 | 648.42 | 2,416.67 | 595.28 | 21,792.43 | 5,380.85 | *99.64%* |
| **III. ការទូទាត់សេវាបំណុល / Debt Service Payment** | **450.89** | **111.96** | **539.99** | **133.71** | **555.16** | **136.86** | **2,920.52** | **721.12** | ***100.00%*** |
| **1. ក្នុងប្រទេស / Domestic** | **4.53** | **1.13** | **2.48** | **0.62** | **0.23** | **0.06** | **67.24** | **16.60** | ***2.30%*** |
| - ប្រាក់ដើម / Principal | 3.76 | 0.94 | 1.60 | 0.40 | - | - | 56.03 | 13.84 | *83.34%* |
| - ការប្រាក់ និងកម្រៃផ្សេងៗ / Interest and Other Fees | 0.77 | 0.19 | 0.88 | 0.22 | 0.23 | 0.06 | 11.20 | 2.77 | *16.66%* |
| **2. ក្រៅប្រទេស / External** (1) | **446.36** | **110.83** | **537.52** | **133.09** | **554.94** | **136.80** | **2,853.28** | **704.51** | ***97.70%*** |
| - ប្រាក់ដើម / Principal | 242.26 | 60.16 | 312.00 | 77.25 | 329.61 | 81.45 | 1,544.94 | 381.47 | *54.15%* |
| - ការប្រាក់ និងកម្រៃផ្សេងៗ / Interest and Other Fees | 204.09 | 50.67 | 225.51 | 55.83 | 225.32 | 55.35 | 1,308.34 | 323.05 | *45.85%* |
| **IV. សន្និធិបំណុល / Outstanding** (2) | **19,483.48** | **4,876.97** | **21,533.88** | **5,284.39** | **22,886.31** | **5,650.94** | **22,886.31** | **5,650.94** | ***100.00%*** |
| - ក្នុងប្រទេស / Domestic | 25.06 | 6.27 | 23.46 | 5.76 | 12.78 | 3.16 | 12.78 | 3.16 | *0.06%* |
| - ក្រៅប្រទេស / External | 19,458.42 | 4,870.69 | 21,510.42 | 5,278.63 | 22,873.53 | 5,647.78 | 22,873.53 | 5,647.78 | *99.94%* |

កំណត់សម្គាល់ / Technical Notes:

*(1)- គិតបញ្ចូលទាំងការទូទាត់សេវាបំណុលនៃបំណុលចាស់ដែលបានដោះស្រាយរួច / Rescheduled old debts are included in the debt service payment*

*(2)- គិតបញ្ចូលទាំងសន្និធិបំណុលចាស់ (ដែលបានដោះស្រាយរួច និងកំពុងចរចាដោះស្រាយ) / Old debts (rescheduled and under negotiation) are included in the outstanding.*

# ផ្នែកទី ១

# បំណុលសាធារណៈក្រៅប្រទេស

# Part 1

# Public External Debt

# ១.១. ការខ្ចី

# 1.1. Borrowing

តារាងទី៥ / Table 5:

## ការខ្ចីតាមវិស័យ / Borrowing by Sector

ឯកតា÷ លាន / Unit: Million

| វិស័យ / Sector | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | SDR | USD | SDR | USD | SDR | USD | SDR | USD | % |
| ហេដ្ឋារចនាសម្ព័ន្ធ / Infrastructure | 427.58 | 661.75 | 481.91 | 701.47 | 530.35 | 739.21 | 4,829.51 | 6,731.51 | *87.94%* |
| វិស័យអាទិភាពផ្សេងទៀត / Other Priority Sectors | 91.39 | 141.44 | 29.30 | 42.65 | 28.12 | 39.19 | 662.13 | 922.90 | *12.06%* |
| សរុប / Total | 518.96 | 803.19 | 511.22 | 744.12 | 558.47 | 778.40 | 5,491.65 | 7,654.40 | ***100.00%*** |

តារាងទី៦ / Table 6:

**ការខ្ចីតាមឥណទាយក / Borrowing by Creditor**

ឯកតា៖ លាន / Unit: Million

| ឥណទាយក / Creditor | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | SDR | USD | SDR | USD | SDR | USD | SDR | USD | % |
| **I. ទ្វេភាគី / Bilateral** | **320.36** | **495.81** | **363.43** | **529.01** | **439.27** | **612.27** | **3,528.55** | **4,918.18** | ***64.25%*** |
| 1. សមាជិកក្លឹបប៉ារីស / Paris Club | 72.70 | 112.52 | 79.68 | 115.98 | 190.73 | 265.85 | 588.59 | 820.39 | *10.72%* |
| - ជប៉ុន / Japan | 54.78 | 84.78 | 79.68 | 115.98 | 137.80 | 192.07 | 519.88 | 724.63 | *9.47%* |
| - បារាំង / France | 17.93 | 27.75 | - | - | 52.94 | 73.79 | 68.71 | 95.77 | *1.25%* |
| 2. មិនមែនសមាជិកក្លឹបប៉ារីស / Non-Paris Club | 247.65 | 383.29 | 283.75 | 413.03 | 248.54 | 346.42 | 2,939.96 | 4,097.79 | *53.54%* |
| - ចិន / China | 181.68 | 281.18 | 255.30 | 371.61 | 208.29 | 290.32 | 2,443.99 | 3,406.50 | *44.50%* |
| - ឥណ្ឌា / India | - | - | - | - | - | - | 53.95 | 75.20 | *0.98%* |
| - កូរ៉េខាងត្បូង / South Korea | 53.85 | 83.35 | 28.46 | 41.42 | 40.25 | 56.10 | 360.96 | 503.12 | *6.57%* |
| - ម៉ាឡេស៊ី / Malaysia | - | - | - | - | - | - | 5.88 | 8.20 | *0.11%* |
| - ថៃ / Thailand | - | - | - | - | - | - | 43.20 | 60.22 | *0.79%* |
| - វៀតណាម / Vietnam | 12.12 | 18.76 | - | - | - | - | 31.97 | 44.56 | *0.58%* |
| **II. ពហុភាគី / Multilateral** | **198.61** | **307.38** | **147.79** | **215.11** | **119.19** | **166.13** | **1,963.10** | **2,736.22** | ***35.75%*** |
| - ធនាគារអភិវឌ្ឍន៍អាស៊ី / ADB | 192.15 | 297.38 | 147.79 | 215.11 | 101.49 | 141.46 | 1,347.56 | 1,878.27 | *24.54%* |
| - ធនាគារពិភពលោក / WB | - | - | - | - | - | - | 495.13 | 690.12 | *9.02%* |
| - មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម / IFAD | - | - | - | - | 17.70 | 24.67 | 62.45 | 87.04 | *1.14%* |
| - មូលនិធិអភិវឌ្ឍន៍នរ៉ឌីក / NDF | - | - | - | - | - | - | 7.88 | 10.99 | *0.14%* |
| - មូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ / OFID | 6.46 | 10.00 | - | - | - | - | 50.08 | 69.80 | *0.91%* |
| **សរុប / Total** | **518.96** | **803.19** | **511.22** | **744.12** | **558.47** | **778.40** | **5,491.65** | **7,654.40** | ***100.00%*** |

តារាងទី៧ / Table 7:

## ការខ្ចីតាមរូបិយប័ណ្ណ / Borrowing by Currency

ឯកតា÷ លាន / Unit: Million

| រូបិយប័ណ្ណ / Currency | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | SDR | USD | SDR | USD | SDR | USD | SDR | USD | % |
| CNY | 181.68 | 281.18 | 22.27 | 32.42 | - | - | 787.18 | 1,097.20 | *14.33%* |
| EUR | 17.93 | 27.75 | - | - | 52.94 | 73.79 | 76.59 | 106.76 | *1.39%* |
| JPY | 54.78 | 84.78 | 79.68 | 115.98 | 137.80 | 192.07 | 519.88 | 724.63 | *9.47%* |
| KRW | - | - | 28.46 | 41.42 | - | - | 260.92 | 363.67 | *4.75%* |
| MYR | - | - | - | - | - | - | 5.88 | 8.20 | *0.11%* |
| SDR | 183.10 | 283.38 | 147.79 | 215.11 | 110.58 | 154.13 | 1,878.91 | 2,618.88 | *34.21%* |
| THB | - | - | - | - | - | - | 43.20 | 60.22 | *0.79%* |
| USD | 81.48 | 126.11 | 233.03 | 339.19 | 257.15 | 358.42 | 1,919.07 | 2,674.86 | *34.95%* |
| សរុប / Total | **518.96** | **803.19** | 511.22 | **744.12** | **558.47** | **778.40** | **5,491.65** | **7,654.40** | ***100.00%*** |

# ១.២. ការដកសាច់ប្រាក់

# 1.2. Disbursement

តារាងទី៨ / Table 8:

## ការដកសាច់ប្រាក់តាមវិស័យ / Disbursement by Sector

ឯកតា÷ លាន / Unit: Million

| វិស័យ / Sector | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | SDR | USD | SDR | USD | SDR | USD | SDR | USD | % |
| ហេដ្ឋារចនាសម្ព័ន្ធ / Infrastructure | 348.87 | 533.44 | 410.15 | 626.77 | 395.11 | 552.58 | 3,336.21 | 4,650.10 | *86.42%* |
| វិស័យអាទិភាពផ្សេងទៀត / Other Priority Sectors | 50.63 | 76.63 | 14.19 | 21.65 | 30.60 | 42.71 | 524.28 | 730.75 | *13.58%* |
| **សរុប / Total** | **399.50** | **610.07** | **424.34** | **648.42** | **425.70** | **595.28** | **3,860.48** | **5,380.85** | ***100.00%*** |

តារាងទី៩ / Table 9:

**ការដកសាច់ប្រាក់តាមឥណទាយក / Disbursement by Creditor**

ឯកតា៖ លាន / Unit: Million

| ឥណទាយក / Creditor | 2013 | | 2014 | | 2015 | | សរុបត្រឹមឆ្នាំ2015 / Accu. as of 2015 | | |
|---|---|---|---|---|---|---|---|---|---|
| | SDR | USD | SDR | USD | SDR | USD | SDR | USD | % |
| **I. ទ្វេភាគី / Bilateral** | **305.45** | **467.25** | **346.71** | **530.25** | **343.96** | **480.84** | **2,442.38** | **3,404.26** | ***63.27%*** |
| 1. សមាជិកក្លឹបប៉ារីស / Paris Club | 15.38 | 23.52 | 31.83 | 49.21 | 47.52 | 65.83 | 184.76 | 257.52 | *4.79%* |
| - ជប៉ុន / Japan | 15.38 | 23.52 | 14.26 | 21.91 | 19.55 | 27.51 | 141.39 | 197.08 | *3.66%* |
| - បារាំង / France | - | - | 17.57 | 27.30 | 27.97 | 38.31 | 43.37 | 60.45 | *1.12%* |
